## សាររបស់អគ្គនាយក

### ការគាំទ្ររបស់លោកអ្នកធ្វើឲ្យការសិក្សារបស់សិស្សបានប្រសើរឡើង

ចំពោះមាតាបិតានិងសិស្សានុសិស្ស ការចាប់ផ្តើមនូវឆ្នាំសិក្សាថ្មីនាំមកនូវអារម្មណ៍លាយគ្នា គឺការរំភើបហើយនិងការថប់បារម្ភខ្លះៗ។ "ប៉ុន្តែ លោកអ្នកប្រហែលជាមានការធូរស្រាលក្នុងចិត្តបើបានដឹងថា មាតាបិតាបានធ្វើសេចក្តីរាយការណ៏មកយើងថា គាត់មានការពេញចិត្តជាខ្លាំងជាមួយអភិបាលសាលានិងគ្រូបង្រៀននៅសាលាកូនគាត់។ គាត់បានឲ្យពិន្ទុខ្ពស់ដល់សាលារៀន ទៅលើផ្នែកសំខាន់ៗ ដូចជាសន្តិសុខ ការថែទាំអាគារសាលារៀននិងទីធ្លារ ហើយនិងគមនាគមន៏រវៀងសាលារៀននិងមាតាបិតាជាដើម។ ជាស្នឹកស្នាប់ មាតាបិតាបានប្រាប់យើងថា កូនគាត់បានត្រូវគ្រូបង្រៀនដាក់កិច្ចការឲ្យធ្វើដែលត្រូវការប្រឹងប្រែងជាខ្លាំង ហើយនិងត្រូវបានលើកទឹកចិត្តឲ្យខិតខំឲ្យអស់ពីសមត្ថភាពផងដែរ។

យើងសូមថ្លែងអំណរគុណដល់ការគាំទ្រនេះ ដែលផ្តល់កម្លាំងឲ្យយើងខិតខំធ្វើឲ្យប្រសើរឡើងថែមទៀត។ គោលដៅចំបងមួយរបស់យើងគឺដើម្បីបញ្ជាក់ថា សិស្សម្នាក់ៗដែលបានរៀនចប់ពីសាលាវិទ្យាល័យ មានជាប់នឹងខ្លួននូវជំនាញដែលចាំបាច់ សម្រាប់ជោគជ័យនៅសាលាមហាវិទ្យាល័យឬសាកលវិទ្យាល័យហើយនិងនៅក្នុងអជីព។ យើងនឹងបន្តដាក់ខ្នាតគំរូខ្ពស់តទៅទៀតសម្រាប់សិស្សទាំងអស់ នៅក្នុងពេលជាមួយគ្នាដែរនេះយើងនឹងផ្តល់ការគាំទ្រ និងការលើកទឹកចិត្តដែលមានសារៈសំខាន់សម្រាប់ធ្វើឲ្យបានសម្រេចនូវគោលដៅទាំងនេះ។

ខ្ញុំសូមឆ្លៀតឱកាសនេះដើម្បីថ្លែងអំណរគុណដល់អ្នករាល់គ្នាដែលបានខិតខំជាខ្លាំងជារៀងរាល់ថ្ងៃដើម្បីជួយសិស្សឲ្យបានទទួលជោគជ័យ។ នេះគឺមានរួមទាំង មាតាបិតាសិស្ស គ្រូបង្រៀន អភិបាលសាលា បុគ្គលិកសាលា ក្រុមហ៊ុនពាណិជ្ជកម្មជាដៃគូរ ហើយនិងអ្នកគាំទ្រពីសហគមន៏ផ្សេងៗ ដែលបានចាត់ដាក់សិស្សជាការសំខាន់ជាងគេ ទោះបីជាមានឧបសគ្គពិបាកៗក៏ដោយ។

ការគាំទ្រដ៏មាំមួនពីមាតាបិតានិងសហគមន៏បានជួយសាលាយើងឲ្យទទួលជោគជ័យខ្ពស់មួយដែលធ្វើឲ្យប្រព័ន្ធសាលារៀនដ៏ទៃទៀតព្យាយាមដេញជើងយើង។ សមិទ្ធិផលរបស់សិស្សបន្តបង្កើនឡើងជាច្រើនតទៅទៀត។ យើងបានប្រើប្រាសដោយប្រសិទ្ធិភាព នូវថវិការដ៏ស្លួតស្តើងបំផុតនៅក្នុងប្រវត្តរដ្ឋកាលីហ្វ័រនីញ៉ា ដែលរដ្ឋបានផ្តល់មកឲ្យយើង ដោយពុំមានធ្វើឲ្យប៉ះពាល់ខូចខាតដល់ការអប់រំ ដូចមានកើតឡើងនៅក្នុងក្រសួងអប់រំដ៏ទៃទៀតឡើយ។ យើងមានសេចក្តីសង្ឃឹមថាឆ្នាំសិក្សាថ្មីនេះនឹងនាំមកនូវជោគជ័យថែមឡើងទៀត។

សូមអរគុណដល់ការទុកចិត្តផ្ញើផ្ដាក់កូនរបស់លោកអ្នកមកដល់សាលារៀនយើងហើយដល់ការបន្តចូលរួមនៅក្នុងការសិក្សារបស់ពួកគេ។ ជាមួយនឹងជំនួយរបស់លោកអ្នក យើងនឹងបន្តផ្តល់ទៅទៀត នូវឱកាសដ៏ត្រចះត្រចង់មួយសម្រាប់អនាគតដ៏ភ្លឺថ្លាសម្រាប់កូនលោកអ្នក គឺការអប់រំដ៏ប្រសើរបំផុត!

ដោយ Christopher J. Steinhauser